# សេចក្ដីណែនាំអំពីការប្រមូលកំហាកពិនិត្យជំងឺ របេង (TB)

## ហេតុអ្វីបានជាយើងចាំបាច់ពិនិត្យកំហាក?

គ្រូពេទ្យរបស់អ្នក ត្រូវការប្រមូលកំហាក ("សារធាតុរាវអន្ទិល") ដែលអ្នកក្អកចេញពីសួត ។ មន្ទីរពិសោធន៍ នឹងយកកំហាក នេះទៅធ្វើតេស្តរកមេរោគរបេង (TB) ។ ការពិនិត្យកំហាកគឺជាវិធីប្រសើរបំផុត ដើម្បីរកមើលថាតើអ្នកមានមេរោគរបេង (TB) ដែរឬទេ ។ បើអ្នកកំពុងប្រើថ្នាំព្យាបាលជំងឺរបេង (TB) ការពិនិត្យកំហាក គឺជាវិធីប្រសើរបំផុត ដើម្បីបញ្ជាក់ថាតើថ្នាំ ដែលអ្នកប្រើមានប្រសិទ្ធិភាពដែរឬទេ ។ ដើម្បីឲ្យប្រាកដថា ការធ្វើតេស្តមានភាពសុក្រិត អ្នកត្រូវប្រឹងក្អកឲ្យកំហាកចេញពី ជម្រៅខាងក្នុងសួតរបស់អ្នក ។ កំហាកដែលចេញពីក្នុងសួតរបស់អ្នក ជាធម្មតាវាមានភាពខាប់ និងស្អិត ។ ទឹកមាត់ជាសារ ធាតុរាវចេញពីក្នុងមាត់របស់អ្នក ហើយវាមានជាតិទឹកច្រើន ហើយមិនខាប់ទេ ។ មិនត្រូវយកទឹកមាត់មកពិនិត្យរកមេរោគ របេងឡើយ ។

**ចំណុចគន្លឹះ ៖ បើអ្នកមិនអាចក្អកចេញកំហាកទេ សូមដកដង្ហើមស្រូបយកចំហាយទឹកក្ដៅសម្រាប់ឆ្អុង ឬដកដង្ហើមយក ចំហាយទឹកក្ដៅដែលអ្នកដាំក្នុងឆ្នាំង ។**

## របៀបប្រមូលសំណាកកំហាក

គ្រូពេទ្យ ឬគិលានុបដ្ឋាករបស់អ្នក នឹងប្រគល់ឲ្យអ្នកនូវពែងប្លាស្ទិកពិសេស សម្រាប់ដាក់កំហាក ។ សូមធ្វើតាមជំហានទាំង អស់នេះដោយប្រុងប្រយ័ត្ន ៖

1. ពែងនេះមិនមានភាពកខ្វក់ឡើយ ។ ហាមបើកពែងនេះ បើអ្នកមិនទាន់ត្រូវការប្រើវាទេនោះ ។
2. ពេលអ្នកងើបពីគេងនៅពេលព្រឹកភ្លាម (មុនពេលផឹក ឬទទួលទានអ្វីមួយចូលពោះ) សូមដុសធ្មេញ និងលាងសំអាត មាត់របស់អ្នកដោយទឹកស្អាត ។ ហាមប្រើទឹកថ្នាំខ្ពុលមាត់ ។
3. បើអាច សូមចេញក្រៅផ្ទះ ឬបើកបង្អួច មុនពេលអ្នកចាប់ផ្ដើមប្រមូលសំណាកកំហាក ។ ការធ្វើបែបនេះ គឺដើម្បីការពារ អ្នកដទៃពីការឆ្លងមេរោគរបេង នៅពេលអ្នកក្អក ។
4. ត្រូវដកដង្ហើមចូលឲ្យវែង រួចទប់ដង្ហើមចំនួន 5 វិនាទី ។ រួចដកដង្ហើមចេញយឺតៗ ។ ដកដង្ហើមចូលឲ្យវែងម្តងទៀត រួច ក្អកឲ្យខ្លាំង រហូតដល់មានកំហាកក្នុងមាត់របស់អ្នក ។
5. ស្តោះកំហាកនោះចូលក្នុងពែងប្លាស្ទិកដែលពេទ្យឲ្យអ្នក ។
6. ត្រូវបន្តធ្វើបែបនេះរហូតដល់អ្នកប្រមូលកំហាករបស់អ្នក ឡើងមកត្រង់ចំណុច 5 មល (ឬច្រើនជាងនេះ) នៃពែងប្លាស្ទិក នោះ ។ បរិមាណនេះ គឺមានចំនួនប្រហាក់ប្រហែលនឹង 1 ស្លាបព្រាកាហ្វេ ។

7. ត្រូវមួលគម្របពែងឲ្យជិតល្អ ដើម្បីកុំឲ្យកំហាកហៀរចេញក្រៅ ។
8. ត្រូវសរសេរថ្ងៃខែឆ្នាំ ប្រមូលកំហាកដាក់លើពែង ។
9. យកពែងនោះដាក់ចូលក្នុងប្រអប់ ឬថង់ដែលពេទ្យឲ្យអ្នក ។
10. រួចយកពែងដែលផ្ទុកកំហាកនោះ មកប្រគល់ឲ្យពេទ្យ ឬគិលានុបដ្ឋាក ។ អ្នកអាចរក្សាពែងដែលផ្ទុកកំហាកក្នុងទូរទឹកកកបានមួយយប់ បើចាំបាច់ ។ តែមិនត្រូវទុកពែងដែលមានផ្ទុកកំហាកក្នុងទូរកក ឬក៏អ្នកអាចទុកវាក្នុងកន្លែងដែលមានសីតុណ្ហភាពធម្មតា ។

Minnesota Department of Health
Tuberculosis Prevention and Control Program
651-201-5414
www.health.state.mn.us/tb

09/22/21 (Khmer) *ដើម្បីស្នើសុំព័ត៌មាននេះក្នុងទ្រង់ទ្រាយផ្សេងសូមហៅទូរស័ព្ទមកលេខ ៖ 651-201-5414 ។*